ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាអនុវត្តគម្រោង

លេខ៖ ១០/០៩ KC-ISC

## រៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកទំនប់ម្ហូង៉ា នៅក្នុងឃុំរយ៉ ស្រុកកោះញ៉ែក ខេត្តមណ្ឌលគីរី

**រវាង**

**ក្រុមប្រឹក្សាឃុំរយ៉ ស្រុកកោះញ៉ែក ខេត្តមណ្ឌលគីរី**

**និង**

**មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ**

**ខេត្តកំពង់ធំ**

ខែឧសភា ឆ្នាំ ២០១០

# កិច្ចសន្យាអនុវត្តគម្រោង

## រៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកទំនប់មួង៉ា
## នៅក្នុងឃុំ រយ៉ ស្រុកកោះញ៉ែក ខេត្តមណ្ឌលគីរី

លេខ៖ ១០/០៩ KC-ISC

កិច្ចសន្យានេះរៀបចំឡើងរវាង ក្រុមប្រឹក្សាឃុំរយ៉ ស្រុកកោះញ៉ែក ខេត្តមណ្ឌលគីរី ជាភាគីម្ចាស់គម្រោង ដែលតំណាងដោយ លោក **ម៉ិល ឌិត** ជាមេឃុំរយ៉ និង មជ្ឈមណ្ឌល សេវាកម្មធារាសាស្ត្រ ជាភាគីអនុវត្តគម្រោង ដែលតំណាងដោយ លោក **សេង សុភ័ត** ជាទីប្រឹក្សា នៃមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ ខេត្តកំពង់ធំ។

### ប្រការ ១ គោលបំណង

១. បង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ចំនួន ១ ដែល មានសមាជិកចូលរួមដោយស្ម័គ្រចិត្ត ប្រមាណ ២១នាក់ ហើយសហគមន៍នេះនឹងមានទុនទ្រទ្រង់ ប្រមាណ ៤២០,០០០រៀល អាចប្រើប្រាស់ជាថវិកាសំរាប់ចាប់ផ្តើម ដំណើរការ និងកែលំអប្រព័ន្ធធារាសាស្ត្ររបស់ពួកគេ។

២. សម្របសម្រួលការរៀបចំគម្រោងប្លង់ទំនប់ ប្រឡាយនិងសំណង់លូនាំទឹក ពីអាងទឹកទំនប់មួង៉ា មកស្រោច ស្រពដីស្រែក្នុងតំបន់ខាងកើតទំនប់ រវាងអ្នកបច្ចេកទេស និងសហគមន៍កសិករប្រើប្រាស់ទឹក។

៣. បណ្តុះបណ្តាលគណៈកម្មាធិការសហគមន៍ និងតំណាងសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីជានាលើប្រសិទ្ធិភាពនៃកិច្ចដំណើរការបែងចែកទឹករវាងសមាជិកសហគមន៍ និងថែទាំប្រព័ន្ធប្រឡាយអោយដំណើរការបានយូរអង្វែង។

សហគមន៍កសិករប្រើប្រាស់ទឹកដែលបង្កើតបាន នឹងទទួលបានការគាំទ្រក្នុងការរៀបចំសេចក្តីព្រាងស្តីអំពីបទបញ្ជាផ្ទៃក្នុង និតិវិធីនៃការប្រមូល និងចុះឈ្មោះសមាជិកក្រុម និតិវិធីជ្រើសរើសថ្នាក់ដឹកនាំសហគមន៍ និងរបៀបរៀបចំប្រជុំសន្និបាតសហគមន៍កសិករប្រើប្រាស់ទឹក។

### ប្រការ ២ ជំហាន និងរយៈពេលនៃការអនុវត្តន៍គម្រោង

ការអនុវត្តន៍គម្រោងនឹងមានរយៈពេល ៨ ខែ ដែលមាន ៧ ជំហានបន្តបន្ទាប់ ដូចខាងក្រោម៖

| | 2010 | | | | | | | |
|---|---|---|---|---|---|---|---|---|
| សកម្មភាព | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ជំហ៊ាន ១: ការរៀបចំក្រុមការងារ និងផ្សព្វផ្សាយព័ត៌មាន | ស3 | | | | | | | |
| ជំហ៊ាន ២: ការចុះឈ្មោះសមាជិកសហគមន៍ | | ស២ | | | | | | |
| ជំហ៊ាន ៣: ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគមន៍ | | ស២ | | | | | | |
| ជំហ៊ាន ៤: ការបោះឆ្នោតជ្រើសរើសតំណាងសហគមន៍ | | ស៣ | | | | | | |
| ជំហ៊ាន ៥: ប្រជុំលើកដំបូង តំណាងសហគមន៍ | | ស៣ | | | | | | |
| ជំហ៊ាន ៦: វគ្គពង្រឹងសមត្ថភាពតំណាងសហគមន៍ | | | ស2-៣ | | សី2 | សី2 | សី2 | |
| ជំហ៊ាន ៧: ការត្រួតពិនិត្យ និងផ្តល់យោបល់បន្ថែម | | | | សី2 | | | | សី2 |

សំរាប់ព័ត៌មានលំអិតស្តីអំពីជំហាននីមួយៗ នៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកនេះ សូមពិនិត្យមើលក្នុង សំណើគម្រោងបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងឃុំរយ៉ មានភ្ជាប់នៅខាងក្រោយកិច្ចសន្យា។

ការអនុវត្តន៍គម្រោងនឹងចាប់ផ្តើមពីថ្ងៃទី២៦ខែមេសា ឆ្នាំ២០១០ រហូតដល់ ថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០១០។

## ប្រការ ៣ ការចំណាយ នៃការអនុវត្តន៍គម្រោង

ការចំណាយលើការអនុវត្តន៍គម្រោងរៀបចំសហគមន៍កសិករប្រើប្រាស់ទឹកក្នុងឃុំរយ៉ ស្រុកកោះញែក ចំនួន១ អស់ប្រាក់សរុបចំនួន **១០១លានរៀល**។ **គម្រោង** JICA-PRDNEP នឹងផ្តល់ប្រាក់ឧបត្ថម្ភលើ ដំណើរការរៀបចំនេះចំនួន **១00 លានរៀល** ។ **ក្រុមប្រឹក្សាឃុំរយ៉** ទទួលខុសត្រូវលើការចំណាយ ចំនួន **១លានរៀល** ។

រាល់ការចំណាយលើដំណើរការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹកក្នុងឃុំរយ៉ នៅក្នុងជំហានទាំង ៧ ដូចមានចែងក្នុងប្រការ ២ នឹងប្រើប្រាស់ថវិកា របស់ **គម្រោង** JICA-PRDNEP ។ នៅក្នុងជំហានទី ៧ បន្ទាប់ពីការវាយតំលៃលើការអនុវត្តន៍គម្រោង របស់មជ្ឈមណ្ឌលសេវាកម្ម ដោយក្រុមការងាររៀបចំសហគមន៍ និងគណៈកម្មាធិការក្រុមកសិករប្រើប្រាស់ទឹក នឹងអនុម័តលើគម្រោងថវិការបស់ក្រុមកសិករប្រើប្រាស់ទឹក ក្នុងប្រជុំសន្និបាតទូទៅនៃសហគមន៍កសិករប្រើប្រាស់ទឹក ក្រុមប្រឹក្សាឃុំរយ៉ នឹងបង់ប្រាក់ចំនួន ១លានរៀល អោយមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ ករណីលទ្ធផលនៃការវាយតំលៃ ទទួលបានជាវិជ្ជមាន និងអាចទទួលយកបានដោយឆ្លើយតបនឹងគោលបំណង ដូចមានចែងក្នុងប្រការ ១។

## ប្រការ ៤ ការបង់ប្រាក់ថ្លៃអនុវត្តគម្រោង

ការបង់ប្រាក់ នឹងត្រូវធ្វើឡើងដោយសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្ទេរប្រាក់ចូលទៅក្នុងគណនីរបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រផ្ទាល់ ចុងជំហានទី៧ បន្ទាប់ពីការវាយតំលៃលើការអនុវត្តន៍គម្រោង ដោយក្រុមការងាររៀបចំសហគមន៍ គណៈកម្មាធិការក្រុមកសិករប្រើប្រាស់ទឹក និងក្រុមប្រឹក្សាឃុំរយ៉។ ករណីលទ្ធផលនៃការវាយតំលៃបង្ហាញថា ដំណើរការរៀបចំក្រុមកសិករប្រើប្រាស់ទឹកនៅក្នុងឃុំរយ៉ មិនអាចធ្វើទៅបាន (មិនមានកសិករចូលជាសមាជិកក្រុមកសិករប្រើប្រាស់ទឹក គ្រប់ចំនួន ២១គ្រួសារ) ក្រុមប្រឹក្សាឃុំរយ៉ មិនចាំបាច់បង់ថ្លៃអនុវត្តគម្រោង អោយមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រឡើយ ហើយកិច្ចសន្យានេះ នឹងត្រូវបញ្ចប់នៅចុងជំហានទី២។

## ប្រការ ៥ របាយការណ៍សកម្មភាព និងរបាយការណ៍បញ្ចប់ការអនុវត្តន៍គម្រោង

នៅពេលចប់ជំហាននីមួយៗ មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ នឹងរាយការណ៍អំពីសកម្មភាពជូនក្រុមប្រឹក្សាឃុំកំរយ៉ ស្តីអំពីដំណើរការនិងលទ្ធផលសំរេចបាន។ ក្រោយពេលបញ្ចប់កិច្ចសន្យា រយៈពេលមួយសប្តាហ៍ មជ្ឈមណ្ឌលនឹងផ្តល់របាយការណ៍បញ្ចប់ការអនុវត្តន៍គម្រោងតាមកិច្ចសន្យា ជូនក្រុមប្រឹក្សាឃុំរយ៉។

ឯកសារព្រាងអំពីបទបញ្ជាផ្ទៃក្នុងក្រុមកសិករប្រើប្រាស់ទឹក និតិវិធីនៃការប្រមូល និងចុះឈ្មោះសមាជិកក្រុម បញ្ជីឈ្មោះ និងប័ណ្ណសមាជិកក្រុមកសិករប្រើប្រាស់ទឹក នឹងត្រូវផ្តល់ជូនគណៈកម្មាធិការក្រុម និងសមាជិកក្រុម។

## ប្រការ ៦ ការវាយតំលៃលើការអនុវត្តន៍គម្រោង

ការវាយតំលៃលើកទី១ នឹងធ្វើឡើង នៅចុងបញ្ចប់នៃជំហានទី ២ (ការរៀបចំ និងចុះឈ្មោះសមាជិកក្រុមកសិករប្រើប្រាស់ទឹក) ដោយក្រុមការងាររៀបចំសហគមន៍ និងក្រុមប្រឹក្សាឃុំរយ៉។ ករណីលទ្ធផលនៃការវាយតំលៃបង្ហាញថា មិនមានកសិករចូលជាសមាជិកក្រុមកសិករប្រើប្រាស់ទឹក គ្រប់ចំនួន ២១គ្រួសារ ស្មើនិង៦៧% នៃកសិករទាំងអស់មានដីក្នុងតំបន់ស្រោចស្រព កិច្ចសន្យានេះ នឹងត្រូវបញ្ចប់នៅចុងជំហានទី២។

ការវាយតំលៃលើកទី២ នឹងធ្វើឡើងនៅក្នុងជំហានទី ៧ ដោយក្រុមការងាររៀបចំសហគមន៍ និងគណៈកម្មាធិការក្រុមកសិករប្រើប្រាស់ទឹក និងក្រុមប្រឹក្សាឃុំរយ៉ ការវាយតំលៃនេះ ផ្តោតសំខាន់ទៅលើពីរចំណុច៖ ១. ការសំរេចនូវគោលបំណង ដូចមានចែងក្នុងប្រការ១ និង ២. ធ្វើការឆ្លុះបញ្ចាំងលើដំណើរការនៃការរៀបចំក្រុមកសិករ ក្នុងឃុំរយ៉ ដើម្បីស្វែងរកចំណុចល្អ និងចំណុចត្រូវកែលំអសំរាប់អនុវត្តទៅថ្ងៃអនាគត។

## ប្រការ ៧ ការដោះស្រាយទំនាស់

ករណីមានទំនាស់កើតឡើងពាក់ព័ន្ធនិងកិច្ចសន្យានេះ ភាគីទាំងពីរ នឹងជួបពិភាក្សាគ្នាដើម្បីរកដំណោះស្រាយសមស្របមួយដែលអាចទទួលបានការឯកភាពពីភាគីទាំងពីរ។ ករណីមិនអាចពិភាក្សា រវាងភាគីទាំងពីរ ទំនាស់នេះ នឹងបញ្ជូនទៅដោះស្រាយតាមវិធានការណ៍ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៨ សុពលភាពនៃកិច្ចសន្យា

កិច្ចសន្យានេះ នឹងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខា រវាងក្រុមប្រឹក្សាឃុំរយ៉ និងទីប្រឹក្សានៃមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រខេត្តកំពង់ធំ។

## ប្រការ ៩ ការធ្វើវិសោធនកម្មនៃកិច្ចសន្យា

កិច្ចសន្យានេះ អាចនឹងត្រូវធ្វើការកែប្រែ ករណីមានការឯកភាពទាំងពីរភាគី រវាងក្រុមប្រឹក្សាឃុំរយ៉ និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

ធ្វើនៅ ឃុំរយ៉ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១០

| មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ | ក្រុមប្រឹក្សាឃុំរយ៉ |
| --- | --- |
| | មេឃុំ |
| ស្រេង_សុគ័ត | ប៊ិល . ប៊ិត |